**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 21-April-2016, 09:40
CMS/CFO: Sann Rada

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

**សំណុំរឿងលេខ** : ០០២/១៩-០៩-២០០៧-អវតក/អជសដ
**ដាក់ទៅ** : អង្គជំនុំជម្រះសាលាដំបូង
**ថ្ងៃដាក់** : ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៦
**ភាគីអ្នកដាក់** : សហព្រះរាជអាជ្ញាអន្តរជាតិ
**ភាសាដើម** : អង់គ្លេស

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ** អមដោយ **ឧបសម្ព័ន្ធសម្ងាត់បំផុត ២**
ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ/Public
ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:
ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:
ឈ្មោះមន្ត្រីដែលបានពិនិត្យ:
ហត្ថលេខា:

---

**ការដាក់បង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិនូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និង កំណត់ហេតុនៃកិច្ចស៊ើបសួរនៅក្នុងសំណុំរឿង០០២**

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញា**
លោក Nicholas KOUMJIAN

**ចម្លងជូន:**
លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះសាលាដំបូង**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យ៉ា សុខន
ចៅក្រម Claudia FENZ
ចៅក្រម យូរ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
លោក ពេជ អង្គ
លោកស្រី Marie GUIRAUD

**ចម្លងជូន:**
**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោកស្រី Anta GUISSÉ

**មេធាវីប្រចាំការ:**
លោកស្រី ទូច វល័ក្ស
លោក Calvin SAUNDERS

**សហចៅក្រមស៊ើបអង្កេត**
ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Michael BOHLANDER

## I. ការដាក់បង្ហាញ

1. សហព្រះរាជអាជ្ញាអន្តរជាតិ (“សហព្រះរាជអាជ្ញា”) តាមរយៈនេះសូមដាក់បង្ហាញកំណត់ហេតុនៃកិច្ចស៊ើបសួរចំនួន ៧ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ១០ និងរបាយការណ៍អង្គភាពគាំពារជនរងគ្រោះចំនួន ៣ ដែលត្រូវបានទទួលយកនៅក្នុងសំណុំរឿង០០៣ និង/ឬ០០៤ ដែលត្រូវគ្នាទៅនឹងកាតព្វកិច្ចនៃការដាក់បង្ហាញរបស់សហព្រះរាជអាជ្ញា នៅក្នុងសំណុំរឿង០០២ (“សម្ភារៈ”)។ រាល់ឯកសារទាំងអស់ត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងឧបសម្ពន្ធសម្ងាត់បំផុតចំនួនពីរ គឺ **ឧបសម្ពន្ធ ក** និង **ឧបសម្ពន្ធ ខ**។

2. សហព្រះរាជអាជ្ញាស្វែងរកការអនុញ្ញាតដាក់បង្ហាញសម្ភារៈ ដែលមាននៅក្នុងការដាក់បង្ហាញនេះ តាមរយៈសំណើចំនួនប្រាំមួយ (រួមគ្នាហៅថា “សំណើ”) ដែលបានដាក់ទៅសហចៅក្រមស៊ើបអង្កេត (“សចស”) នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥[1], ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៥[2], ថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៥[3] ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥[4] និងថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥[5]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (“សចសអ”) បានអនុញ្ញាតឲ្យមានការដាក់បង្ហាញសំណើនេះទាក់ទងទៅនឹងឯកសារ ដែលបច្ចុប្បន្ននេះកំពុងត្រូវបានដាក់បង្ហាញនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥[6],

---

[1] សំណុំរឿង003-**D100/13** សំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី និងរបាយការណ៍ពីផ្នែកគាំពារជនរងគ្រោះនៃសំណុំរឿង០០៣ ដែលទាក់ទងនឹងជនជាតិចាម ចូលទៅក្នុងសំណុំរឿង០០២, ១១ សីហា ២០១៥។

[2] សំណុំរឿង003- **D100/14** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី និងរបាយការណ៍ផ្នែកគាំពារជនរងគ្រោះនៃសំណុំរឿងលេខ០០៣ ទៅក្នុងសំណុំរឿងលេខ០០២, ១៣ សីហា ២០១៥។ សំណុំរឿង004-**D193/38** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី និងរបាយការណ៍អង្គភាពគាំពារជនរងគ្រោះនៃសំណុំរឿងលេខ០០៤ ទៅក្នុងសំណុំរឿងលេខ០០២, ១៣ សីហា ២០១៥។

[3] សំណុំរឿង004- **D193/45** សំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង០០៤ ទៅក្នុងសំណុំរឿង០០២, ៧ តុលា ២០១៥។

[4] សំណុំរឿង004- **D193/46** សំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង០០៤ ទៅក្នុងសំណុំរឿង ០០២, ១៦ តុលា ២០១៥។

[5] សំណុំរឿង004- **D193/48** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង០០៤ ទៅក្នុងសំណុំរឿង០០២, ២១ តុលា ២០១៥។

[6] សំណុំរឿង004- **D193/61**ដីកាសម្រេចលើសំណើ D193/29, D193/35, D193/38, D193/39, D193/42, D193/45, D193/46 និង D193/48 របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសារ, ១៧ ធ្នូ ២០១៥។

ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦[7] និងថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៦[8] ("សេចក្តីសម្រេច")។ សេចក្តីសម្រេចទាំងនោះត្រូវបានចែកចាយជូនទៅអង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃចេញផ្សាយ។

3. សហព្រះរាជអាជ្ញាបានកត់សម្គាល់អំពីសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងទៅនឹងកាតព្វកិច្ចនៃការដាក់បង្ហាញរបស់សហព្រះរាជអាជ្ញា នៅក្នុងសំណុំរឿង០០២/០២ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥[9]។ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់សហព្រះរាជអាជ្ញា ឱ្យដាក់បង្ហាញដល់អង្គជំនុំជម្រះនេះ និងភាគីនានា នូវភ័ស្តុតាងដោះបន្ទុកពីសំណុំរឿង០០៣ និង០០៤ ដោយឈរលើមូលដ្ឋានជាបន្តបន្ទាប់ រហូតដល់មានការបញ្ចប់សំណុំរឿង០០២/០២[10]។ វាក៏បានបង្គាប់ផងដែរដល់សហព្រះរាជអាជ្ញា ឱ្យដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយនៃសំណុំរឿង០០៣ និង០០៤ របស់រាល់បុគ្គលទាំងអស់ដែលត្រូវបានស្នើសុំឱ្យមកផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២/០២[11]។ ក្រោយមក អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា សម្ភារៈបន្ថែមណានៅក្នុងសំណុំរឿង០០៣ និង០០៤ ដែលសហព្រះរាជអាជ្ញាមានបំណងចង់ដាក់ ដោយអនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង ត្រូវបានដាក់បង្ហាញនៅពេលពាក្យសុំមានសម្អាងហេតុ អនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង[12]។

4. សហព្រះរាជអាជ្ញាក៏បានកត់សម្គាល់ផងដែរ អំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៥ ស្តីពីសំណើរបស់ នួន ជា ទាក់ទងទៅនឹងកាតព្វកិច្ចនៃការដាក់បង្ហាញរបស់សហព្រះរាជអាជ្ញា នៅក្នុងសំណុំរឿង០០២/០១[13]។ ដោយឡែក អង្គជំនុំជម្រះ

---

[7] សំណុំរឿង003- **D100/17** សេចក្តីសម្រេចលើសំណើសុំដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញាអន្តរជាតិ D100, D100/2, D100/10, D100/13, D100/14, និង D100/16, ២៨ មករា ២០១៦។

[8] សំណុំរឿង003- **D100/18** សេចក្តីសម្រេចរួមលើសំណើសុំដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញាអន្តរជាតិ, ២៩ មករា ២០១៦។

[9] **E363/3** សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី ខៀវ សំផន ពាក់ព័ន្ធនឹងកាតព្វកិច្ចដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញា, ២២ តុលា ២០១៥។

[10] *ដដែល ដូចខាងលើ*, កថាខណ្ឌ ២១-២៤, ផ្នែកសម្រេចសេចក្តី, EN 01157631-33, 01157640-41។

[11] *ដដែល ដូចខាងលើ*, កថាខណ្ឌ ២៥-២៧, ផ្នែកសម្រេចសេចក្តី, EN 01157634-35, 01157640-41។

[12] *ដដែល ដូចខាងលើ*, កថាខណ្ឌ ២៨-៣០, ផ្នែកសម្រេចសេចក្តី, EN 01157635-36, 01157640-41។

[13] **F2/4/2** សេចក្តីសម្រេចលើផ្នែកខ្លះនៃសំណើលើកទីបីរបស់ នួន ជា សុំទទួលយក និងពិចារណាទៅលើភស្តុតាងបន្ថែមក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០១ , ១៦ មីនា ២០១៥, ផ្នែកសម្រេចសេចក្តី, EN 01075186។

តុលាការកំពូលបានបង្គាប់ឱ្យសហព្រះរាជអាជ្ញាដាក់បង្ហាញជូនទៅអង្គជំនុំជម្រះតុលាការកំពូល និងភាគីនានានូវភស្តុតាងនានាដែល៖ (i) បានផ្តល់ដោយសាក្សីដែលបានធ្វើការដោយផ្ទាល់ជាមួយនឹង រស់ ញឹម, ឬ (ii) ទាក់ទងនឹងការប្រឆាំងរបស់ភូមិភាគពាយ័ព្យចំពោះ ប៉ុល ពត និង នួន ជា នៅមុនថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

5. សហព្រះរាជអាជ្ញាបានកំពុងពិនិត្យមើលឯកសារនានាដែលអនុញ្ញាតឱ្យដាក់បង្ហាញ ដើម្បីកំណត់ថាតើឯកសារមួយណាត្រូវតាមលក្ខខណ្ឌដែលបានរៀបរាប់ខាងលើ។ នៅក្នុងឧបសម្ពន្ធនានាអមជាមួយ សហព្រះរាជអាជ្ញាបានបង្ហាញនៅក្នុងជួរឈរក្រោមចំណងជើងថា "ក្រុមដាក់បង្ហាញ" មូលហេតុសម្រាប់ការដាក់បង្ហាញឯកសារ។ ពាក្យសុំអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងណាមួយ នឹងត្រូវដាក់តាមក្រោយក្នុងពេលវេលាសមស្រប។

6. អង្គជំនុំជម្រះសាលាដំបូងបានណែនាំថា ជាដំបូង សហព្រះរាជអាជ្ញាត្រូវដាក់សំណើសុំបង្ហាញរបស់ខ្លួនទៅអង្គជំនុំជម្រះ ដោយប្តឹងពីភ័ស្តុតាងដែលខ្លួនចង់ដាក់បង្ហាញ បន្ទាប់មកទើបដាក់សំណើទៅអង្គជំនុំជម្រះសាលាដំបូង សុំឱ្យទទួលយកឯកសារណាមួយ ទុកជាការអនុម័តសម្រាប់ការដាក់បង្ហាញឯកសារ[14]។

7. អង្គជំនុំជម្រះសាលាដំបូង ធ្លាប់បានបង្គាប់ពីមុនថា គ្រប់ការដាក់បង្ហាញឯកសារទាំងអស់ ពីសំណុំរឿង០០៣ និង០០៤ ទៅក្នុងសំណុំរឿង០០២ គប្បីដាក់ និងជូនដំណឹងទៅអង្គជំនុំជម្រះសាលាដំបូងជាបណ្តោះអាសន្នដោយឈរលើមូលដ្ឋានសម្ងាត់បំផុត និងថាបន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងនឹងធ្វើការកំណត់ចំពោះឯកសារនោះ ថាតើគប្បីដាក់ចំណាត់ថ្នាក់ឡើងវិញថា សម្ងាត់ ឬក៏អត់[15]។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាសូមជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង អំពីឯកសារដែលមាននៅក្នុង **ឧបសម្ពន្ធ ក** ដោយឈរលើមូលដ្ឋានសម្ងាត់បំផុត។

---

14 **E127/7/1** ព័ត៌មានពាក់ព័ន្ធនឹងចម្លើយសាក្សីសំណុំរឿង០០៣ និងសំណុំរឿង០០៤ ដែលអាចពាក់ព័ន្ធនឹងសំណុំរឿង០០២, ១៦ សីហា ២០១៣, កថាខណ្ឌ២។

15 **E127/4** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី "ការបង្ហាញអំពីចម្លើយសាក្សីសម្រាប់សាក្សីដែលអាចផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០២", ២៤ មករា ឆ្នាំ២០១២, ទំព័រ១។

8. ការផ្ដល់សិទ្ធិឱ្យដាក់បង្ហាញសម្ភារៈនៅក្នុង**ឧបសម្ព័ន្ធ ក** គឺត្រូវស្ថិតនៅក្រោមលក្ខខណ្ឌតម្រូវនានាដែលបានកំណត់ដោយ សចសអ ដូចតទៅ៖[16]

ក. រាល់សម្ភារៈទាំងអស់ត្រូវចាត់ទុកជាសម្ងាត់។

ខ. ក្នុងករណីដែលសម្ភារៈត្រូវបានទទួលយកជាភស្តុតាងនៅក្នុងសំណុំរឿង០០២/០២ សម្ភារៈទាំងអស់នោះត្រូវចាត់ទុកជាសម្ងាត់។

គ. សម្ភារៈទាំងនោះ មិនត្រូវផ្សព្វផ្សាយឱ្យលើសពីបុគ្គលទាំងឡាយ ដែលបានកំណត់អត្តសញ្ញាណ យ៉ាងជាក់ច្បាស់នៅក្នុងលក្ខខណ្ឌតម្រូវនានាដែលមានចែងនៅក្នុងនោះទេ។

ឃ. ក្នុងករណីដែលមានសាក្សី ដែលកំណត់ហេតុស្ដាប់ចម្លើយរបស់ខ្លួន ត្រូវបានអនុញ្ញាតឱ្យដាក់បង្ហាញនៅក្នុង**ឧបសម្ព័ន្ធ ក** ត្រូវបានកោះហៅមកផ្ដល់សក្ខីកម្មនោះ ពួកគេអាចធ្វើដូច្នេះបានក្នុងសវនាការបើកចំហរ ដរាបណាឈ្មោះរបស់ពួកគេ និងព័ត៌មានកំណត់អត្តសញ្ញាណផ្សេងទៀតត្រូវបានរក្សាជាសម្ងាត់ ហើយពួកគាត់ត្រូវបានកំណត់អត្តសញ្ញាណតែតាមរហស្សនាមសម្រាប់សំណុំរឿង០០២/០២។

ង. សម្ភារៈដែលបានផ្ដល់នៅក្នុង**ឧបសម្ព័ន្ធ ក** មិនត្រូវផ្សព្វផ្សាយទៅកាន់សាធារណៈជន ក្នុងទម្រង់ណាមួយ ឬតាមរយៈមធ្យោបាយសារព័ត៌មានបែបណាក៏ដោយ ឱ្យលើសពីភស្តុតាងដែលបានបង្ហាញក្នុងសវនាការបើកចំហររបស់តុលាការឡើយ។

ច. ភាគីណាក៏ដោយ ក្រុមមេធាវីការពារក្ដី ឬបុគ្គលដទៃទៀត ដែលត្រូវអាន លើកយោង ឬបើមិនដូច្នោះទេ ប្រើប្រាស់ឯកសារនានាដែលបានដាក់បង្ហាញនៅក្នុង**ឧបសម្ព័ន្ធ ក** ត្រូវកំណត់អត្តសញ្ញាណសាក្សី តែដោយរហស្សនាមដែលបានដាក់ឱ្យសម្រាប់សំណុំរឿង០០២/០២ និងត្រូវប្រើប្រាស់តែការរៀបរាប់ផ្សេងៗ ដែលបានគណនាសមហេតុសមផលប៉ុណ្ណោះ ដើម្បីចៀសវាងនូវការកំណត់អត្តសញ្ញាណសាក្សីរូបនោះ តាមរយៈព័ត៌មានដទៃទៀត។

ឆ. សម្ភារៈទាំងនោះត្រូវផ្ដល់ជូនទៅមេធាវីការពារក្ដីរបស់ជនជាប់ចោទទាំងពីររូប មេធាវីប្រចាំការរបស់ ខៀវ សំផន (“មេធាវីប្រចាំការ”) និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី តាមរយៈសំណៅថតចម្លងអេឡិកត្រូនិច។

[16] សេចក្ដីសម្រេច, កថាខណ្ឌ៣២។

ជ. មេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវដាក់បង្ហាញសម្ភារៈឲ្យទៅតែសមាជិកនៃក្រុមការងាររបស់ពួកគាត់ ដែលទទួលបានការងារជាផ្លូវការ តាមវិធាន២២(៥) និងវិធាន១២(៤)*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង និងកម្មសិក្សាការីដែលត្រូវបានចាត់តាំងជាផ្លូវការប៉ុណ្ណោះ។

ឈ. មេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនត្រូវបានអនុញ្ញាតឲ្យបោះពុម្ព ផលិតឡើងវិញ ថតចម្លង ស្កេន ឬបើមិនដូច្នោះទេ ធ្វើការថតចម្លងនៃឯកសារដើមដែលពួកគេបានទទួលឡើយ ក្រៅពីសម្រាប់ការប្រើប្រាស់ផ្ទៃក្នុងនៃឯកសារនោះ ដោយសមាជិកនៃក្រុមនានារបស់ខ្លួនដែលត្រូវបានណែនាំ ឬត្រូវបានអនុញ្ញាតឲ្យចូលពិនិត្យមើលសម្ភារៈសម្ងាត់នោះប៉ុណ្ណោះ។

ញ. មេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវរក្សាកំណត់ហេតុ, តាមរបៀបមួយដែលអាចត្រូវបានពិនិត្យឡើងវិញ, នូវសំណៅដែលដែលពួកគេបានបោះពុម្ព ផលិតឡើងវិញ ថតចម្លង ស្កេន ឬបើមិនដូច្នោះទេ ថតចម្លង សម្រាប់ប្រើប្រាស់ផ្ទៃក្នុង។

ដ. ប្រសិនបើសមាជិកណាម្នាក់នៃភាគីនានា ឬអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង ០០២/០២ ដឹងអំពីសំណៅគ្មានការអនុញ្ញាតណាមួយនៃសម្ភារៈដែលបានអនុញ្ញាតឲ្យដាក់បង្ហាញទាំងនេះ សមាជិករូបនោះត្រូវចាត់គ្រប់វិធានការទាំងអស់ជាបន្ទាន់ដើម្បីរក្សាការពារសុវត្ថិភាព និងប្រគល់សំណៅសម្ភារៈឯកសារនោះជូន សចស វិញ។

ឋ. ប្រសិនបើសមាជិកណាម្នាក់នៃភាគីនានា ឬអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង ០០២/០២ ដឹងអំពីការរំលោភបំពានលក្ខខណ្ឌ និងការដាក់កម្រិតទាំងនេះ សមាជិករូបនោះត្រូវរាយការណ៍អំពីការរំលោភបំពាននោះជូន សចស។

9. ការផ្តល់សិទ្ធិឲ្យដាក់បង្ហាញសម្ភារៈនៅក្នុង**ឧបសម្ព័ន្ធ ខ** គឺត្រូវស្ថិតនៅក្រោមលក្ខខណ្ឌតម្រូវខាងលើនេះ ក៏ប៉ុន្តែសម្រាប់ពីកថាខណ្ឌ ឃ ដល់ ច ដែលបានប្រែប្រួលទៅកាន់ការកំណត់ដ៏តឹងរឹងដូចទៅ៖

ក. ក្នុងករណីដែលសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី ដែលឯកសាររបស់គាត់ត្រូវបានអនុញ្ញាតឱ្យដាក់បង្ហាញនៅក្នុង **ឧបសម្ព័ន្ធ ខ** ត្រូវបានកោះហៅឱ្យមកផ្តល់សក្ខីកម្ម ពួកគាត់ត្រូវធ្វើដូច្នោះនៅក្នុងសវនាការសម្ងាត់។

ខ. មិនមានឯកសារដែលបានផ្តល់នៅក្នុង **ឧបសម្ព័ន្ធ ខ** ណាមួយ ត្រូវបានផ្សព្វផ្សាយទៅកាន់សាធារណជនក្នុងទម្រង់ណាមួយ ឬតាមរយៈមធ្យោបាយសារព័ត៌មានបែបណាក៏ដោយ ឬត្រូវបានបង្ហាញ ឬយោងនៅក្នុងសវនាការបើកចំហររបស់តុលាការ ទៅតាមរបៀបណាក៏ដោយ។

គ. ភាគីណាក៏ដោយ ក្រុមមេធាវីការពារក្តី ឬបុគ្គលដទៃទៀត ដែលត្រូវអាន លើកយោង ឬបើមិនដូច្នោះទេ ប្រើប្រាស់ឯកសារនានាដែលបានដាក់បង្ហាញនៅក្នុង**ឧបសម្ព័ន្ធ ខ** ត្រូវស្នើសុំធ្វើសវនាការជាសម្ងាត់ជាមុនសិន ហើយនៅក្នុងករណីណាក៏ដោយ ត្រូវកំណត់អត្តសញ្ញាណសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី តែដោយរហស្សនាមដែលបានដាក់ឱ្យសម្រាប់សំណុំរឿង ០០២/០២ និងត្រូវប្រើប្រាស់តែការរៀបរាប់ផ្សេងៗ ដែលបានគណនាសមហេតុសមផលប៉ុណ្ណោះ ដើម្បីចៀសវាងនូវការកំណត់អត្តសញ្ញាណសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីរូបនោះតាមរយៈព័ត៌មានដទៃទៀត។

## II. ដំណោះស្រាយដែលស្នើឡើង

10. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាសូមស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ទទួលយក និងដាក់បញ្ចូលទៅក្នុងសំណុំរឿង០០២ នូវឯកសារដូចបានកំណត់អត្តសញ្ញាណក្នុង **ឧបសម្ព័ន្ធ ក** និង **ឧបសម្ព័ន្ធ ខ**៕

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៦ | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |